**ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ**
**THE PEOPLE MOVEMENT FOR DEMOCRACY**
*ពលរដ្ឋខ្លាំង ជាតិខ្លាំង*
**STRONG PEOPLE   STRONG NATION**

លេខ: ០០៣/២០២១ ច.ព.ជ.

សហរដ្ឋអាមេរិក ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

# សេចក្តីថ្លែងការណ៍

## គាំទ្ររបាយការណ៍ ស្តីពីនីតិរដ្ឋ ឆ្នាំ២០២១ នៃ គម្រោងយុត្តិធម៌ពិភពលោក

*ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ* សូមគាំទ្រការចេញផ្សាយ *របាយការណ៍ស្តីពីនីតិរដ្ឋឆ្នាំ២០២១* នៃ *គម្រោងយុត្តិធម៌ពិភពលោក* ដែលមានមូលដ្ឋាននៅរដ្ឋធានីវ៉ាស៊ីនតុនឌីស៊ី នៃសហរដ្ឋអាមេរិក ដឹកនាំដោយលោក William C. Hubbard អតីតប្រធានសមាគមច្បាប់អាមេរិកាំង រួមនឹងសហការីជំនាញច្បាប់នៅជុំវិញពិភពលោក។

*របាយការណ៍ស្តីពីនីតិរដ្ឋឆ្នាំ២០២១* នៃ*គម្រោងយុត្តិធម៌ពិភពលោក* បានរកឃើញកម្ពុជានៅចំណាត់ថ្នាក់លេខទី១៣៨ ក្នុងចំណោម១៣៩ប្រទេស ដែលអនុវត្តនីតិរដ្ឋអាក្រក់ជាងគេ ហើយចំណាត់ថ្នាក់នេះ ពុំមានការប្រែប្រួលប្រៀបធៀបទៅនឹង *របាយការណ៍ស្តីពីនីតិរដ្ឋឆ្នាំ២០២០*។ ស្ថានភាពនីតិរដ្ឋកម្ពុជាអន់បំផុត បើប្រៀបធៀបនឹងបណ្តាប្រទេសនៅក្នុងតំបន់ ដូចជា ប្រទេសឥណ្ឌូនេស៊ី នៅចំណាត់ថ្នាក់ទី៦៨, ថៃ ទី៨០, វៀតណាម ទី៨៨, ហ្វីលីពីន ទី១០២ និងប្រទេសភូមា ជាប់ចំណាត់ទី១២៨។

*របាយការណ៍ស្តីពីនីតិរដ្ឋ* នេះ គូសបញ្ជាក់ថា ការរឹតបន្តឹងលើអំណាចរដ្ឋាភិបាល (កុំឲ្យហួសហែងលើប្រព័ន្ធដឹកនាំជាតិ), ការទប់ស្កាត់អំពើពុករលួយ, ការដឹកនាំជាតិដោយបើកចំហ, ការគោរពសិទ្ធិជាមូលដ្ឋាន (របស់ពលរដ្ឋខ្មែរ), បរិយាកាសជាបញ្ញត្តិ (បញ្ញត្តិប្រតិបត្តិនានារបស់រដ្ឋាភិបាល), យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋ និង យុត្តិធម៌ផ្នែកព្រហ្មទណ្ឌ កត្តាទាំងអស់នេះ នៅមានកំរិតទាបបំផុតសម្រាប់កម្ពុជា ទោះបីសណ្តាប់ធ្នាប់និងសន្តិសុខសង្គម មានកំរិតលើមធ្យមបន្តិច។

*ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ* មើលឃើញថា ចំណុចជាបទដ្ឋានវិនិច្ឆ័យទាំងនេះ ឆ្លុះបញ្ចាំងពីការអនុវត្តច្បាប់នៅកម្ពុជា ដែលអាស្រ័យលើមាត់មេដឹកនាំម្នាក់ (ឬ*នីតិមាត់*) ដើម្បីត្រួតត្រានីតិរដ្ឋនៃប្រទេសជាតិ ដោយល្បែងបំភ្លាត់បំភ្លៃតាមនយោបាយបុគ្គល ធ្វើឲ្យយុត្តិធម៌សង្គមជាតិនៅក្រោមបំណងនយោបាយរបស់បុគ្គល។

ការរកឃើញ នៃ*គម្រោងយុត្តិធម៌ពិភពលោក* ត្រូវនឹងភាពជាក់ស្តែងនៅក្នុងសង្គមខ្មែរ ៖

- ការចាប់ខ្លួនប្រធានគណបក្សសង្គ្រោះជាតិ លោក *កឹម សុខា* និងការបន្តបិទសិទ្ធិនយោបាយរបស់គាត់ ការរំលាយគណបក្សសង្គ្រោះជាតិ ការហាមឃាត់សិទ្ធិនយោបាយនៃមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ ការរំលោភយកអាសនៈសភា និងក្រុមប្រឹក្សាឃុំ/សង្កាត់ ចំនួន៥០០៧នាក់ របស់គណបក្សសង្គ្រោះជាតិ ។

- ការបន្តចាប់ខ្លួន ការឃុំខ្លួន និងការដាក់គុកដ៏អយុត្តិធម៌ ទៅលើសកម្មជនសង្គម សកម្មជនបរិស្ថាន សកម្មជនសិទ្ធិមនុស្ស សកម្មជនប្រជាធិបតេយ្យ ដូចជា លោក *រ៉ុង ឈុន* លោក *សួង សុភ័ណ្ឌ* ព្រះសង្ឃ *កើត សារ៉ាយ* អ្នកស្រី *ឈឿន ដារ៉ាវី* កញ្ញា *អេង ម៉ាឡៃ* (ហៅ សូ មេត្តា) លោក *មាន ព្រហ្មមុនី* លោក *មួង សុភក្រ្ត* លោក *ថា ឡាវី* លោក *ហ៊ុន វណ្ណៈ* លោក *ថុន រដ្ឋា* កញ្ញា *ឡុង គន្ធា* កញ្ញា *ភួន កែវរស្មី* ... ។

- អំពើឃាតកម្មក្រៅប្រព័ន្ធច្បាប់ បាញ់សម្លាប់សកម្មជនសង្គម ក្រុមមេដឹកនាំសហជីព ព្រះសង្ឃ អ្នកកាសែត និងសិល្បការិនី ដូចជា លោកបណ្ឌិត *កែម ឡី* លោក *ឈុត វុទ្ធី* ព្រះសង្ឃ *សំ ប៊ុនធឿន* លោក *ជា វិជ្ជា* លោក *រស់ សុវណ្ណារេត* លោក *ហ៊ី វុទ្ធី* លោក *យើម សំបូរ* លោក *ធន់ ប៊ុនលី* លោក *ឈរ ចិត្រធារិទ្ធ* អ្នកស្រី *ពិសិដ្ឋ ពីលិកា* ការបាញ់ប្រហារលើកញ្ញា *ទូច ស៊ុននិច* ព្រមទាំង ការជះទឹកអាស៊ីទៅលើអ្នកស្រី *ភាគ ម៉ារីណា* ... ។

- អំពើឃាតកម្មក្រៅប្រព័ន្ធច្បាប់ បាញ់សម្លាប់អ្នកនយោបាយ សកម្មជននយោបាយ ពលទាហាន នាយទាហាន និងមន្ត្រីជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច រួមមានលោក *ហូ សុខ* លោក *និម វណ្ណសានី* លោក *ចៅ សម្បត្តិ* លោក *លី សេងហុង* លោក *ក្រូច យឿម* លោក *ជា ឫទ្ធីឈុត* លោក *ម៉ែន ប៊ុនថន* ... និងការគប់គ្រាប់បែកលើក្រុមបាតុករ នៅខាងមុខមន្ទីររដ្ឋសភា ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧។

ជនរងគ្រោះទាំងអស់នេះ នៅមិនទាន់ទទួលបានយុត្តិធម៌នៅឡើយទេ។ ស្ថានភាពបែបនេះ គឺជាការបំពានដ៏ធ្ងន់ធ្ងររយៈពេល៣០ឆ្នាំមកនេះ លើគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១, សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស, កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំង រដ្ឋធម្មនុញ្ញកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

លើសពីនេះទៀត ការរំលោភសិទ្ធិមនុស្ស និងការបំផ្លាញលទ្ធិប្រជាធិបតេយ្យកម្ពុជា នៅតែបន្តធ្លាក់ក្នុងស្ថានភាពកាន់តែអាក្រក់ ដូចឃើញការប្រព្រឹត្តបំពានជាក់ស្តែងក្នុងពេលបច្ចុប្បន្ន ដោយអាជ្ញាធររដ្ឋាភិបាល និងចេញពីមាត់បញ្ជារបស់ប្រមុខរដ្ឋាភិបាល សម្តេច *ហ៊ុន សែន* ដូចជាការគំរាមប្រមាថជីវិតពលរដ្ឋ ការវាយរាងកាយធ្ងន់ធ្ងរ ការតាមវាយដល់ផ្ទះ ការវាយកម្ទេចចោល ការវាយខ្នោះ និង ការចាប់ដាក់គុកជាដើម។

ការគ្រប់គ្រងនិងចាត់ចែងព្រទ្យសម្បត្តិជាតិ ត្រូវប្រើប្រាស់សម្រាប់តែបុព្វហេតុប្រយោជន៍នយោបាយគ្រួសារមេដឹកនាំក្នុងប្រព័ន្ធឧក្រិដ្ឋកម្មពុករលួយបក្ខពួកនិយម ហើយមិនបានផលដោយសមធម៌ ដល់ប្រជាពលរដ្ឋខ្មែរជាម្ចាស់ប្រទេសឡើយ ស្របពេលធនធានធម្មជាតិរបស់កម្ពុជា ស្ថិតនៅក្នុងស្ថានភាពអន្តរាយយ៉ាងធំធេង។ ស្ថាប័នរដ្ឋ ប្រៀបដូចជាក្រុមហ៊ុនផាច់ថ្លៃរបស់ប្រមុខរដ្ឋាភិបាល ហើយកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការទូទៅ ប្រៀបដូចជាឧបករណ៍របស់គ្រួសារមេដឹកនាំប្រទេសដូច្នេះ ធ្វើឲ្យប្រទេសជាតិធ្លាក់ខ្សោយដុនដាបគ្រប់វិស័យ រហូតដល់ជាតិកម្ពុជា ដែលមានប្រជាពលរដ្ឋប្រមាណ១៦លាននាក់ ពលរដ្ឋខ្មែរពេញកម្លាំងយ៉ាងតិច២លាននាក់ នាំគ្នាធ្វើចំណាកស្រុក ខ្លះប្រថុយឆ្លងដែនខុសច្បាប់ ជាពិសេស ទៅប្រទេសថៃ គ្រាន់តែដើម្បីទៅរកការងារចិញ្ចឹមជីវិតនៅក្រៅប្រទេស និងជួយទំនុកបម្រុងជីវភាពគ្រួសារដ៏ក្រីក្រនៅកម្ពុជា។

*ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ* យល់ឃើញថា រដ្ឋាភិបាលកម្ពុជានៃសម្តេច *ហ៊ុន សែន* ត្រូវលើកកម្ពស់ការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ឡើងវិញ ដើម្បីស្តារសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេសស្តារមុខមាត់កិត្តិយសប្រទេសជាតិ ឱ្យដើរលើផ្លូវនីតិរដ្ឋថ្លៃថ្នូរ ជាជាងធ្វើប្រតិកម្មខឹងសម្បានឹងរបាយការណ៍វាយតម្លៃប្រកបដោយបច្ចេកទេសរបស់ *គម្រោងយុត្តិធម៌ពិភពលោក*។

**ប្រធានប្រតិបត្តិ**

**ទូច ទិបុល**